# 소망의 여인들

## Prayer Calander

2025년 7월

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់



### ការអធិស្ឋានសម្រាប់គ្រួសារ

Botswana ជាប្រទេសមួយដែលគ្មានផ្លូវគោកនៅអាហ្វ្រិកខាងត្បូង ហើយរដ្ឋធានីរបស់វាមានឈ្មោះថា Gaborone។ វាជាប្រទេសមួយក្នុងចំណោមប្រទេសប្រជាធិបតេយ្យមួយចំនួននៅអាហ្វ្រិក។ គ្រិស្ទានជាសាសនាដ៏សំខាន់មួយដែលមានចំនួន 70% នៃប្រជាជន។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏ស្ត្រីនៅទីនោះនៅតែប្រឈមមុខនឹងបញ្ហាជាច្រើន បូករួមជាមួយនឹងការទទួលបានការអប់រំ ការថែទាំសុខភាព និងសេដ្ឋកិច្ចដែលមានកម្រិត។ បទដ្ឋានសង្គមមួយនេះតែងតែដាក់បន្ទុកដែលគ្មានភាពស្មើរគ្នាទៅលើស្ត្រីអោយជាអ្នកមើលថែ ស្របពេលដែលពួកគេបានកំណប់សមត្ថភាពរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ខ្លួនឯង។ ពីរភាគបីនៃស្ត្រីនៅ Botswana បានជួបប្រទះការរំលោភបំពាន ដែលមានភាគរយច្រើនជាងទ្វេដងនៃមធ្យមភាគជាសកល។ កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមបានដោះស្រាយបញ្ហាប្រឈមទាំងនេះដោយជំរុញអោយមានការលូតលាស់ខាងព្រលឹងវិញ្ញាណ និងការព្យាបាលផ្នែកអារម្មណ៍ ដោយផ្តល់ឱ្យពួកគេនូវក្តីសង្ឃឹមជាថ្មីតាមរយះកម្មវិធី។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. ព្រះវរបិតាអើយ
សូមបញ្ចប់អត្រានៃអំពើហិង្សាខ្ពស់នៃយេនឌ័រនៅក្នុងទីក្រុង Selebi-Phikwe ប្រទេស Botswana
ជាពិសេសចំពោះស្ត្រីគ្រីស្ទានដែលមានស្វាមីដែលមិនមែនជាអ្នកជឿ។ (រ៉ូម ៨:១៨)

2. ព្រះអម្ចាស់អើយ សូមប្រទានអោយមានការរីកចម្រើនផ្នែកវប្បធម៌
និងនីតិបញ្ញត្តិនៅក្នុងប្រទេសប៊ូរុនឌី
ដើម្បីឱ្យស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការកាន់កាប់ទ្រព្យសម្បត្តិ
និងទទួលបានមរតករបស់ពួកគេ។ (សុភាសិត ៣១:១៦)

3. បិតាអើយ
កូនអធិស្ឋានសូមឱ្យស្ត្រីនៅកូម៉ូរ៉ូមានសមត្ថភាពដូចបុរសក្នុងការទទួលបានការអប់រំ និងការថែទាំសុខភាពប្រកបដោយគុណភាព។ (កាឡាទី ៣:២៨)

4. ព្រះអង្គអើយ ទូលបង្គំអធិស្ឋានសូមឱ្យទ្រង់ជួយដល់ស្ត្រីនៅ Djibouti ឱ្យមានឱកាសក្នុងការធ្វើការងារដែលអាចផ្លាស់ប្តូជីវភាពពួកគេពីភាពក្រីក្រផងដែរ។ (ភីលីព ៤:១៩)

5. ព្រះអម្ចាស់អើយ
ទូលបង្គំអធិស្ឋានសូមឱ្យទ្រង់ផ្តល់នូវការអប់រំដែលមានប្រសិទ្ធភាព
និងការថែទាំសុខភាពដល់ស្ត្រីនៅក្នុងប្រទេសអេរីទ្រាផងដែរ។ (យេរេមា ៣៣:៦)

6. សូមឱ្យស្ត្រីមេម៉ាយនៅ Eswatini
ទទួលបានកិត្តិយសនិងការពារពីការបង្អាប់មាក់ងាយ។ ឱ ព្រះវរបិតាអើយ
សូមផ្គត់ផ្គង់តម្រូវការរបស់ពួកគេ ហើយផ្តល់សេចក្តីយុត្តិធម៌ដល់ពួកគេ ។ (ទំនុកតម្កើង ៦៨:៥)

7. ព្រះអម្ចាស់អើយ សូមអនុញ្ញាតឱ្យក្មេងស្រី
និងស្ត្រីនៅអាហ្វ្រិកខាងត្បូងអាចស្វែងរកគុណតម្លៃរបស់ពួកគេនៅក្នុងទ្រង់
ហើយទទួលយកការពិតដែលទ្រង់បានរាប់ពួកគេថាជាអ្វីដែលគួរឱ្យស្ញប់ស្ញែង
និងអស្ចារ្យ។ (ទំនុកតម្កើង ១៣៩:១៤)

8. ព្រះជាអម្ចាស់អើយ សូមពង្រឹងបេសកកម្មនៅ Norea Media
និងដៃគូរបស់ពួកគេ
ក្នុងការដែលពួកគេនៅតែបន្តការបណ្តុះបណ្តាលអំពីរបួសចាស់ទៅដល់ស្ត្រីនៅ Zanzibar និង Pemba ។
សូមដឹកនាំវគ្គបណ្តុះបណ្តាលសម្រាប់អ្នកដឹកនាំដែលប្រព្រឹត្តទៅក្នុងខែតុលាឆ្នាំ 2025នេះផងដែរ។ (លូកា 4:18)

9. បិតាអើយ
កូនអធិស្ឋានសុំឱ្យស្ត្រីនៅក្នុងប្រទេសកេនយ៉ាត្រូវបានរួមបញ្ចូលនៅក្នុងដំណើរការនៃការធ្វើការសម្រេចចិត្តនានា
និងតួនាទីជាអ្នកដឹកនាំនៅក្នុងគ្រប់កិច្ចការនៅក្នុងជីវិតរបស់ពួកគេ។ (សុភាសិត ៣១:២៦)

10. ព្រះជាអម្ចាស់អើយ
យើងអធិស្ឋានសុំឱ្យអំពើហិង្សាក្នុងគ្រួសារនៅម៉ាដាហ្គាស្ការត្រូវបានបញ្ចប់
ដើម្បីឱ្យស្ត្រីទីនោះទទួលបានយុត្តិធម៌
និងការគាំទ្រដែលពួកគេត្រូវការផងដែរ។ (ទំនុកតម្កើង ៤៦:៥)

11. ព្រះអម្ចាស់អើយ
សូមបំបែករនាំងនៃវប្បធម៌ដែលស្ត្រីនៅជនបទនៃប្រទេសម៉ាឡាវីកំពុងតែជួបប្រទះក្នុងការទទួលបានការថែទាំសុខភាពត្រឹមត្រូវរបស់អ្នកម្តាយនៅក្នុងប្រទេសម៉ាឡាវី។
សូមឲ្យសហគមន៍របស់ពួកគេផ្តល់ការថែទាំប្រកបដោយសុវត្ថិភាព
និងសេចក្តីថ្លៃថ្នូរសម្រាប់ពួកគេ។ (ទំនុកតម្កើង ២៨:៧)

12. ព្រះអង្គអើយ
សូមធ្វើការនៅក្នុងចិត្តរបស់អ្នកដែលមិនឱ្យតម្លៃស្ត្រីនៅប្រទេសម៉ូរីស។
សូមឲ្យការរើសអើងយេនឌ័រនៅកន្លែងធ្វើការត្រូវបានលុបបំបាត់ចោលផងដែរ។ (រ៉ូម ២:១១)


**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 hskim@twrk.or.kr

13. ព្រះអម្ចាស់អើយ
សូមឲ្យគ្រួសារដែលដឹកនាំដោយស្ត្រីនៅក្នុងប្រទេសម៉ូសំប៊ិក
យកឈ្នះលើភាពក្រីក្រ
និងទទួលបានធនធានគ្រប់គ្រាន់ក្នុងការជួយគ្រួសាររបស់ពួកគេឱ្យមានការរីកចម្រើន។ (ទំនុកតម្កើង ៣៤:៦)

14. ឱ ព្រះវរបិតាអើយ សូមទ្រង់ជួយបុរសនៅប្រទេសរវ៉ាន់ដាឱ្យយល់ និងរួបរួមគ្នាជាមួយភរិយារបស់ពួកគេក្នុងការមានទំនួលខុសត្រូវសំខាន់ៗនៃការថែទាំគ្រួសារ និងផ្ទះរបស់ពួកគេ។ (ម៉ាថាយ ១១:២៨)

15. ព្រះអម្ចាស់អើយ
សូមនាំមកនូវការរួបរួមដោយសេចក្តីស្រឡាញ់ដល់អាពាហ៍ពិពាហ៍នៅក្នុងប្រទេសតង់ហ្សានី។ សូមអោយប្តីប្រពន្ធ
អាចស្វែងរកសេចក្តីសុខសាន្តក្នុងគ្រួសាររបស់គេ។ (ម៉ាឡាគី ២:១៦)

16. ព្រះអង្គអើយ
សូមនាំមកនូវការប្រោសឱ្យជាដល់ជនរងគ្រោះក្នុងប្រទេសអ៊ូហ្គង់ដានៃអំពើហឹង្សាដែលផ្អែកលើយេនឌ័រ។ សូមឱ្យសំឡេងរបស់ពួកគេត្រូវបានឮ
និងនាំមកនូវការផ្លាស់ប្តូរដល់សង្គមជាតិរបស់ពួកគេផងដែរ។ (ទំនុកតម្កើង ១០៣:៦)

17. ឱព្រះវរបិតាអើយ សូមឲ្យសេចក្តីស្រឡាញ់
និងការប្រោសឱ្យជារបស់ទ្រង់បានស្តារឡើងវិញនៅក្នុងដួងចិត្តដែលខ្ទិចខ្ទាំរបស់កុមារនៅ Eswatini ដែលជួបប្រទះនឹងការប៉ះទង្គិចដោយសារអំពើហឹង្សា ភាពក្រីក្រ ឬការបាត់បង់។ សូមប្រទានអោយពួកគេនូវក្តីសង្ឃឹម សុវត្ថិភាព និងសន្តិភាពផងដែរ។ (យេរេមា ១៧:១៤)

18. ព្រះវរបិតាអើយ ក្នុងអំណាចព្រះចេស្តារបស់ទ្រង់
សូមលុបបំបាត់នូវអំពើហឹង្សាដែលអាហ្វ្រិកខាងត្បូងកំពុងតែជួបប្រទះ ក៏ដូចជាឧក្រិដ្ឋកម្ម អំពើហឹង្សាផ្អែកលើយេនឌ័រ និងការធ្វើអត្តឃាត។
សូមនាំយកការផ្លាស់ប្តូរដល់ដួងចិត្តរបស់ជនល្មើសទាំងនោះ។ (កាឡាទី ៥:១៩-២១)

19. ព្រះអម្ចាស់អើយ យើងខ្ញុំអធិស្ឋានសុំឲ្យមានការផ្លាស់ប្តូរនូវបរិបទ ឬវប្បធម៌ ដែលធ្វើឲ្យស្ត្រីជាច្រើនគ្មានការងារធ្វើនៅក្នុងប្រទេសសូម៉ាលី។
សូមជួយអោយស្ត្រីម្នាក់ៗនៅទីនោះ បានស្វែងរកសេរីភាព
ដើម្បីឈានដល់ការបង្ហាញសក្តានុពលពិតប្រាកដ
និងពេញលេញរបស់ពួកគេ។ (ទំនុកតម្កើង ៩:៩)

20. កូនសូមអរព្រះគុណទ្រង់ ព្រះជាម្ចាស់អើយ
ដែលទ្រង់បានប្រើភាពក្លាហាន និងប្រាជ្ញារបស់មេដឹកនាំស្ត្រី
ក្នុងការជំរុញអោយមានសន្តិភាពនៅក្នុងប្រទេសស៊ូដង់ខាងត្បូង។
សូមទ្រង់ប្រទានពរដល់ការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការនាំមកនូវការផ្សះផ្សាជាតិរបស់ពួកគេផងដែរ។ (ម៉ាថាយ ៥:៩)

21. បិតាអើយ
កូនអធិស្ឋានទូលសូមទ្រង់ធ្វើការក្នុងជីវិតរបស់ស្ត្រីនៅក្នុងប្រទេសតង់ហ្សានីដែលប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារដែលមានសភាពធ្ងន់ធ្ងរជាខ្លាំង។ (១កូរិនថូស ១៣:៤-៧)

22. ព្រះអម្ចាស់ អើយ ក្នុងនាមជាគ្រិស្តបរិស័ទនៅ Zanzibar និង Pemba ដែលជាជនជាតិភាគតិចដែលមានភាពដាច់ដោយឡែកពីគេនៅក្នុងសង្គម សូមពង្រឹងសេចក្តីជំនឿ និងប្រទានកម្លាំងដល់ពួកគេឱ្យមានការតស៊ូ
និងចូលរួមក្នុងដំណើរការនៃការធ្វើការសម្រេចចិត្តរបស់រដ្ឋាភិបាលនៅទីនោះ។ (រ៉ូម ៥:៣-៥)

23. ព្រះជាម្ចាស់អើយ សូមឲ្យឱកាសទទួលបានការអប់រំ
និងហិរញ្ញវត្ថុត្រូវបានស្តារឡើងវិញ ដល់ស្ត្រី Zambian
ដែលបានបាត់បង់ការងារ
និងការសិក្សាត្រូវបានបញ្ឈប់ក្នុងរដូវកាលកូវីឌ១៩។ (សុភាសិត ១:៥)

24. ព្រះអម្ចាស់អើយ
សូមប្រទានកម្លាំងដល់លោកយាយនៅក្នុងប្រទេសហ្ស៊ីមបាវ៉េដែលមើលថែចៅរបស់ពួកគេ
ក្នុងកំឡុងពេលដែលឪពុកម្តាយពួកគេធ្វើកាចំណាកស្រុករជាពលករនៅក្នុងប្រទេសជិតខាងផងដែរ។ (អេសាយ ៤០:៣១)

25. ព្រះអង្គអើយ សូមទ្រង់ប្រទានប្រាជ្ញាដល់អ្នកដឹកនាំ Eswatini ក្នុងការដែលពួកគេកំពុងស្វែងរកបញ្ហាប្រឈមនៃការកាត់បន្ថយការផ្តល់fund ដែលអាចប៉ះពាល់ដល់វិស័យថែទាំសុខភាព។ (យ៉ាកុប ១:៥)

26. ឱ ព្រះវរបិតាអើយ
យើងអធិស្ឋានសម្រាប់ការស្តារឡើងវិញនៃការងារនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសអាហ្វ្រិកខាងត្បូង ដើម្បីអោយប្រជាជន
ជាពិសេសយុវជនវ័យកណ្តាលអាចស្វែងរកការងារធ្វើ
និងផ្គត់ផ្គង់ជីវភាពរបស់ខ្លួនគេផងដែរ។ (២ថែស្សាឡូនិច ៣:១០-១២)

27. ព្រះអង្គអើយ សូមប្រទានឱកាសក្នុងជីវិតរបស់ស្ត្រីនៅអ៊ូហ្គង់ដា
ដែលប្រឈមមុខនឹងឧបសគ្គក្នុងការអប់រំ ការថែទាំសុខភាព
និងសុខុមាលភាពហិរញ្ញវត្ថុផងដែរ។ (ទំនុកតម្កើង ១៤៦:៧)

28. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់មន្ត្រីរដ្ឋាភិបាលនៅ Zanzibar និង Pemba
នៅពេលដែលពួកគេស្វែងរកការបង្កើតការងារសម្រាប់ប្រជាជនរបស់ពួកគេ
ក្នុងការកាត់បន្ថយភាពក្រីក្រ។ (ចោទិយកថា ៨:១៨)

29. ព្រះអម្ចាស់អើយ សូមផ្តល់ការច្នៃប្រឌិតដល់យុវជននៃ Eswatini
ដើម្បីកំណត់កម្មវិធីប្រើប្រាស់ជំនាញរបស់ពួកគេ
ដើម្បីបង្កើតអាជីវកម្មនៅក្នុងសហគមន៍របស់ពួកគេផងដែរ។ (កូឡុស ៣:២៣)

30. ព្រះអង្គអើយ សូមប្រទានកូនដែលបាត់ខ្លួនទៅនៅអាហ្វ្រិកខាងត្បូង
ជូនដល់ឪពុកម្តាយដែលសោកសៅវិញ។
សូមឲ្យអ្នកមានទោសត្រូវបានកាត់ទោស
និងទទួលបានការផ្លាស់ប្រែនៅក្នុងទ្រង់។ (យេរេមា ៣១:១៧)

31. ព្រះអម្ចាស់អើយ 98% នៃស្ត្រីនៅក្នុងក្រុមអធិស្ឋាន Zingwe Zingwe នៅលើកោះ Zanzibar គឺមិនចេះអក្សរនោះទេ។
សូមប្រទានអោយពួកគេមានរបៀបនៃការរៀនអាន
ដើម្បីអោយពួកគេអាចអធិស្ឋានតាមរយៈប្រតិទិនអធិស្ឋានប្រចាំថ្ងៃ
និងអានព្រះគម្ពីបានផងដែរ។ (សុភាសិត ៤:១៣)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**